# លីមីត និង ភាពជាប់នៃអនុគមន៍

## សម្រាប់ថ្នាក់ទី ១២

$$\lim_{x \to 0} \frac{1 - \cos(ax)}{x^2} = \frac{a^2}{2}$$

រៀបរៀងដោយ លឹម ផល្គុន និង សែន ពិសិដ្ឋ

រក្សាសិទ្ធិ

# លីមីត និង ភាពជាប់នៃអនុគមន៍

## សម្រាប់ថ្នាក់ទី ១២

រៀបរៀងដោយ លឹម ផល្គុន
Tel: 017 768 246
www.mathtoday.wordpress.com

# គណៈកម្មការនិពន្ធ និង រៀបរៀង

លឹម ផល្គុន និង សែន ពិសិដ្ឋ

# គណៈកម្មការត្រួតពិនិត្យបច្ចេកទេស

លោក យ៉ង់ ឆារី
លោក លឹម ឆុន
លោក អ៊ឹង សំណាង

# គណៈកម្មការត្រួតពិនិត្យអក្ខរាវិរុទ្ធ

លោក លឹម មិត្តសិរ

# ការិយកុំព្យូទ័រ

លោកស្រី លី គុណ្ណាកា លោក អ៊ឹង សំណាង

# អារម្ភកថា

សួស្តីមិត្តអ្នកសិក្សាជាទីស្រលាញ់រាប់អាន !
សៀវភៅ **លីមីត និង ភាពជាប់នៃអនុគមន៍** ដែលលោកអ្នកកំពុងតែកាន់អាននេះខ្ញុំបាទបានរៀបចំឡើងសម្រាប់ទុកជាឯកសារសម្រាប់អ្នកសិក្សាដែលមានបំណងចង់ចេះ លើផ្នែកនៃមេរៀននេះឲ្យបានកាន់តែច្បាស់ ។
នៅក្នុងសៀវភៅនេះរួមមាន មេរៀនសង្ខេប លំហាត់គំរូ និង លំហាត់អនុវត្តន៍សម្រាប់អ្នកសិក្សាហ្វឹកហាត់ដោះស្រាយដោយខ្លួនឯង។

យើងខ្ញុំសង្ឃឹមថា សៀវភៅមួយក្បាលនេះ នឹងអាចចូលរួមផ្តល់នូវគំនិត និង វិធីសាស្ត្រថ្មីៗក្នុងការដោះស្រាយលំហាត់ផ្នែក លីមីត និង ភាពជាប់នៃអនុគមន៍ ចំពោះលោកអ្នកសិក្សាជាពុំខានឡើយ ។

ជាទីបញ្ចប់ខ្ញុំបាទសូមជូនពរចំពោះលោកអ្នក សូមមានសុខភាពល្អ មានប្រាជ្ញាឈ្លាសវៃ និង ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច ។


បាត់ដំបងថ្ងៃទី១៨ វិច្ឆិការ ឆ្នាំ២០១១
អ្នកនិពន្ធ និង ស្រាវជ្រាវ
**លឹម ផល្គុន**
Tel : 017 768 246
Email: lim_phalkun@ymail.com
Website: www.mathtoday.wordpress.com

ជំពូកទី១

# លីមីតនៃអនុគមន៍

## ១-លីមីតនៃអនុគមន៍ត្រង់ចំនួនកំណត់

**និយមន័យ១** ៖ អនុគមន៍ $f$ មានលីមីត $L$ កាលណា $x$ ខិតជិត $a$ បើគ្រប់ចំនួន $\varepsilon > 0$ មានចំនួន $\delta > 0$ ដែល $0 < |x - a| < \delta$ នាំឲ្យ $|f(x) - L| < \varepsilon$ ។ គេកំណត់សរសេរ $\lim_{x \to a} f(x) = L$ ។

**ឧទាហរណ៍** ដោយប្រើនិយមន័យបង្ហាញថា $\lim_{x \to 2}(3x + 4) = 10$ ?

យើងត្រូវបង្ហាញថា ចំពោះគ្រប់ចំនួន $\varepsilon > 0$ មាន $\delta > 0$ ដែល

$|(3x + 4) - 10| < \varepsilon$ កាលណា $0 < |x - 2| < \delta$ ។

គេបាន $|(3x + 4) - 10| < \varepsilon \Leftrightarrow |3(x - 2)| < \varepsilon$ គ្រប់ $\varepsilon > 0$

សមមូល $|x - 2| < \frac{\varepsilon}{3}$ យក $\delta = \frac{\varepsilon}{3}$ នោះ $|x - 2| < \delta$ ។

សម្រាយនេះបញ្ជាក់ថា $\varepsilon > 0$ មាន $\delta = \frac{\varepsilon}{2} > 0$ ដែល $|x - 2| < \delta$

នាំឲ្យ $|(3x + 4) - 10| < \varepsilon$ ។ ដូចនេះ $\lim_{x \to 2}(3x + 4) = 10$ ។

**និយមន័យ** ២៖ អនុគមន៍ $f$ ខិតទៅរក $+\infty$ ឬ $-\infty$ កាលណា $x$ ខិតជិត $a$ បើគ្រប់ចំនួន $M>0$ មានចំនួន $\delta>0$ ដែល $0<|x-a|<\delta$ នាំឲ្យ $f(x)>M$ ឬ $f(x)<-M$ ។

គេកំណត់សរសេរ $\lim_{x\to a} f(x)=+\infty$ ឬ $\lim_{x\to a} f(x)=-\infty$ ។

**ឧទាហរណ៍** គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{2x+3}{x-2}$

ចូរស្រាយតាមនិយមន័យថា $\lim_{x\to 2^+} f(x)=+\infty$ ។

គេមាន $f(x)=\dfrac{2x+3}{x-2}=\dfrac{2(x-2)+7}{x-2}=2+\dfrac{7}{x-2}$

យើងនឹងរកគចំនួន $M>0$ ដែល $f(x)>M$ ។

ដើម្បីឲ្យ $f(x)>M$ យើងគ្រាន់តែឲ្យ $\dfrac{7}{x-2}>M$ និង $x>2$

គេទាញបាន $0<x-2<\dfrac{7}{M}$ យក $\delta=\dfrac{7}{M}>0$ នោះ $0<x-2<\delta$

សម្រាយនេះបញ្ជាក់ថាគ្រប់ចំនួន $M>0$ មាន $\delta=\dfrac{7}{M}>0$

ដែល $0<|x-2|<\delta$ នាំឲ្យ $f(x)>M$ ។ដូចនេះ $\lim_{x\to 2^+} f(x)=+\infty$ ។

# លំហាត់អនុវត្តន៍

ចូរស្រាយបញ្ជាក់លីមីតខាងក្រោមតាមនិយមន័យ ៖

១/ $\lim_{x\to 3}(2x+1)=7$

២/ $\lim_{x\to -2}(x+5)=3$

៣/ $\lim_{x\to 2}(3x+2)=8$

៤/ $\lim_{x\to 1}(-2x+7)=5$

៥/ $\lim_{x\to 2}(x^2+1)=5$

៦/ $\lim_{x\to 1}(x^2+2x+4)=7$

៧/ $\lim_{x\to 1}\frac{3x+1}{x^2+1}=2$

៨/ $\lim_{x\to 2}\sqrt{x^3+1}=3$

៩/ $\lim_{x\to 2}(3^x+1)=10$

១០/ $\lim_{x\to \frac{\pi}{2}}(\sin x)=1$

១១/ $\lim_{x\to 0^+}\frac{x+1}{x}=+\infty$

១២/ $\lim_{x\to 1^+}\frac{2x+1}{x-1}=+\infty$

១៣/ $\lim_{x\to 2^-}\frac{x+2}{x-2}=-\infty$

១៤/ $\lim_{x\to 1^-}\frac{3x}{x-1}=-\infty$

១៥/ $\lim_{x\to 1}\frac{2x^2-4x+5}{(x-1)^2}=+\infty$

១៦/ $\lim_{x\to 2}\frac{x^2-4x}{x^2-4x+4}=-\infty$

១៧/ $\lim_{x\to 8}(\sqrt[3]{x}+1)=3$

១៨/ $\lim_{x\to 2}(x^3+2x)=12$

# ២-លីមីតនៃអនុគមន៍ត្រង់អនន្ត

**និយមន័យ១** ៖ អនុគមន៍ $f$ មានលីមីត $L$ កាលណា $x$ ខិតទៅ $+\infty$ ឬ $-\infty$ បើគ្រប់ចំនួន $\varepsilon > 0$ មានចំនួន $N > 0$ ដែល $x > N$ ឬ $x < -N$ នាំឲ្យ $|f(x) - L| < \varepsilon$ ។

គេកំណត់សរសេរ $\lim\limits_{x\to+\infty} f(x) = L$ ឬ $\lim\limits_{x\to-\infty} f(x) = L$ ។

ឧទាហរណ៍ គេមានអនុគមន៍ $f$ កំណត់ដោយ $f(x) = \dfrac{4x+1}{2x+3}$

ចូរស្រាយថា $\lim\limits_{x\to-\infty} f(x) = 2$ និង $\lim\limits_{x\to+\infty} f(x) = 2$ ។

គេមាន $f(x) = \dfrac{4x+1}{2x+3} = \dfrac{2(2x+3)-5}{2x+3} = 2 - \dfrac{5}{2x+3}$

នាំឲ្យ $|f(x) - 2| = \dfrac{5}{|2x+3|}$ ចំពោះ $|f(x) - 2| < \varepsilon$ , $\varepsilon > 0$

គេបាន $\dfrac{5}{|2x+3|} < \varepsilon$ នាំឲ្យ $|2x+3| > \dfrac{5}{\varepsilon}$

គេទាញ $\left[\begin{array}{l} 2x+3 > \dfrac{5}{\varepsilon} \\ 2x+3 < -\dfrac{5}{\varepsilon} \end{array}\right.$ សមមូល $\left[\begin{array}{l} x > \dfrac{5}{2\varepsilon} - \dfrac{3}{2} \\ x < -\dfrac{5}{2\varepsilon} - \dfrac{3}{2} \end{array}\right.$

ហេតុនេះ គ្រប់ $\varepsilon > 0$ មាន $A = \frac{5}{2\varepsilon}$ ឬ $A = \frac{5}{2\varepsilon} + \frac{3}{2}$

ដែល $x > A$ ឬ $x < -A$ នាំឲ្យ $|f(x) - 2| < \varepsilon$

ដូចនេះ $\lim_{x \to -\infty} f(x) = 2$ និង $\lim_{x \to +\infty} f(x) = 2$ ។

**និយមន័យ២** ៖ អនុគមន៍ $f$ មានលីមីត $+\infty$ កាលណា $x$ ខិតទៅ $+\infty$ បើគ្រប់ចំនួន $M > 0$ មានចំនួន $N > 0$ ដែល $x > N$ នាំឲ្យ $f(x) > M$ ។

គេកំណត់សរសេរ $\lim_{x \to +\infty} f(x) = +\infty$ ។

**និយមន័យ៣** ៖ អនុគមន៍ $f$ មានលីមីត $+\infty$ កាលណា $x$ ខិតទៅ $-\infty$ បើគ្រប់ចំនួន $M > 0$ មានចំនួន $N > 0$ ដែល $x < -N$ នាំឲ្យ $f(x) > M$ ។

គេកំណត់សរសេរ $\lim_{x \to -\infty} f(x) = +\infty$ ។

# លំហាត់អនុវត្តន៍

ចូរស្រាយបញ្ជាក់លីមីតខាងក្រោមតាមនិយមន័យ ៖

១/ $\lim\limits_{x\to+\infty}\frac{3x+2}{x+1}=3$

២/ $\lim\limits_{x\to-\infty}\frac{1-3x}{x+2}=-3$

៣/ $\lim\limits_{x\to+\infty}\frac{5x+2}{1-x}=-5$

៤/ $\lim\limits_{x\to-\infty}\frac{4x+1}{2x+1}=2$

៥/ $\lim\limits_{x\to+\infty}\frac{x^2}{x^2+1}=1$

៦/ $\lim\limits_{x\to-\infty}\frac{8x+1}{1-4x}=-2$

៧/ $\lim\limits_{x\to-\infty}(2x+3)=-\infty$

៨/ $\lim\limits_{x\to+\infty}(-2x+3)=-\infty$

៩/ $\lim\limits_{x\to+\infty}(x^2+4)=+\infty$

១០/ $\lim\limits_{x\to-\infty}(x^3)=-\infty$

១១/ $\lim\limits_{x\to+\infty}\frac{2x-x^2}{3x+5}=-\infty$

១២/ $\lim\limits_{x\to-\infty}\frac{x^2+1}{x+1}=-\infty$

១៣/ $\lim\limits_{x\to+\infty}\frac{2}{x+1}=0$

១៤/ $\lim\limits_{x\to-\infty}\frac{7}{x+1}=0$

១៥/ $\lim\limits_{x\to+\infty}\frac{x^2+4x}{x^2+4x+5}=1$

១៦/ $\lim\limits_{x\to-\infty}\frac{4}{(x-2)^2}=0$

# ៣-ប្រមាណវិធីលើលីមីត

បើ $\lim_{x\to a} f(x) = L$ , $\lim_{x\to a} g(x) = M$ និង $\lim_{x\to a} h(x) = N$

ដែល L , M និង N ជាចំនួនពិតនោះគេបាន ៖

ក/ $\lim_{x\to a}[f(x) + g(x) - h(x)] = L + M - N$

ខ/ $\lim_{x\to a}[\alpha f(x) + \beta g(x) - \gamma h(x)] = \alpha L + \beta M - \gamma N$

គ/ $\lim_{x\to a}[f(x)g(x)h(x)] = L.M.N$

ឃ/ $\lim_{x\to a}[\frac{f(x)}{g(x)}] = \frac{L}{M}$ ដែល $M \neq 0$

# ៤-លីមីតនៃអនុគមន៍អសនិទាន

រូបមន្ត ៖

1/ $\lim_{x\to a} \sqrt[n]{x} = \sqrt[n]{a}$ ដែល $a \geq 0$ និង $n \in IN$ , $n \geq 2$

2/ $\lim_{x\to a} \sqrt[n]{x} = \sqrt[n]{a}$ ដែល $a < 0$ និង $n \in IN$ , $n \geq 2$(ចំនួនគត់សេស)

3/ $\lim_{x\to a} \sqrt[n]{f(x)} = \sqrt[n]{\lim_{x\to a} f(x)}$ ដែល $a \geq 0$ និង $n \in IN$ , $n \geq 2$

ឧទាហរណ៍ គណនាលីមីត

១/ $\lim\limits_{x\to 2}\sqrt{x^3+1}=\sqrt{\lim\limits_{x\to 2}(x^3+1)}=\sqrt{2^3+1}=\sqrt{9}=3$

២/ $\lim\limits_{x\to 3}\sqrt[3]{\dfrac{x^2+5x+3}{x+5}}=\sqrt[3]{\lim\limits_{x\to 3}\dfrac{x^2+5x+3}{x+5}}$

$$=\sqrt[3]{\frac{9+15+3}{5+3}}=\sqrt[3]{\frac{27}{8}}=\frac{3}{2}$$

៣/ $\lim\limits_{x\to 2}(\sqrt{x^3+4x}+\sqrt[3]{x^2+3x-2})$

$$=\sqrt{\lim_{x\to 2}(x^3+4x)}+\sqrt[3]{\lim_{x\to 2}(x^2+3x-2)}$$

$$=\sqrt{8+8}+\sqrt[3]{4+6-2}=4+2=6$$

## លំហាត់អនុវត្តន៍ ៖

គណនាលីមីត ៖

1/ $\lim\limits_{x\to 4}\sqrt[3]{\dfrac{x^2-3x+4}{2x^2-x-1}}$

2/ $\lim\limits_{x\to -3}\sqrt{\dfrac{x^2-9}{2x^2+7x+3}}$

3/ $\lim\limits_{x\to 4}\sqrt[3]{\dfrac{x+4}{-7x+1}}$

4/ $\lim\limits_{x\to 2}\sqrt{x+\sqrt{x+\sqrt{x+2}}}$

# ៥-លីមីតនៃអនុគមន៍បណ្តាក់

បើ f និង g ជាអនុគមន៍ពីរដែលមានលីមីត $\lim\limits_{x\to a} g(x) = L$

និង $\lim\limits_{x\to L} f(x) = f(L)$ នោះ $\lim\limits_{x\to a} f[g(x)] = f(L)$ ។

ឧទាហរណ៍១ គណនាលីមីត $\lim\limits_{x\to 2} \ln(\frac{4x+7}{x+3})$

តាង $g(x) = \frac{4x+7}{x+3}$ និង $f(x) = \ln x$ នោះ $f[g(x)] = \ln(\frac{4x+7}{x+3})$

គេមាន $\lim\limits_{x\to 2} g(x) = \lim\limits_{x\to 2} \frac{4x+7}{x+3} = \frac{8+7}{2+3} = 3$

ដូចនេះ $\lim\limits_{x\to 2} f[g(x)] = \lim\limits_{x\to 3} f(x) = f(3) = \ln 3$ ។

ឧទាហរណ៍2 គណនាលីមីត $\lim\limits_{x\to +\infty} \ln(\frac{4x+7}{x+3})$

តាង $g(x) = \frac{4x+7}{x+3}$ និង $f(x) = \ln x$ នោះ $f[g(x)] = \ln(\frac{4x+7}{x+3})$

គេមាន $\lim\limits_{x\to +\infty} g(x) = \lim\limits_{x\to +\infty} \frac{4x+7}{x+3} = \lim\limits_{x\to +\infty} \frac{4+\frac{7}{x}}{1+\frac{3}{x}} = \frac{4}{1} = 4$

ដូចនេះ $\lim\limits_{x\to +\infty} f[g(x)] = \lim\limits_{x\to 4} f(x) = \lim\limits_{x\to 4} \ln x = \ln 4 = 2\ln 2$ ។

# ៦-លីមីតតាមការប្រៀបធៀប

1/ បើ f និង g ជាអនុគមន៍ពីរ ហើយ A ជាចំនួនពិតមួយដែល

ចំពោះ $\forall x \geq A : f(x) \geq g(x)$ និង $\lim\limits_{x \to +\infty} g(x) = +\infty$

នោះ $\lim\limits_{x \to +\infty} f(x) = +\infty$ ។

2/ បើ f និង g ជាអនុគមន៍ពីរ ហើយ A ជាចំនួនពិតមួយដែល

ចំពោះ $\forall x \geq A : f(x) \leq g(x)$ និង $\lim\limits_{x \to +\infty} g(x) = -\infty$

នោះ $\lim\limits_{x \to +\infty} f(x) = -\infty$ ។

3/ បើ f ,g និង h ជាអនុគមន៍បី ហើយ A ជាចំនួនពិតមួយដែល

$\forall x \geq A : g(x) \leq f(x) \leq h(x)$ និង $\lim\limits_{x \to +\infty} g(x) = \lim\limits_{x \to +\infty} h(x) = \lambda$

នោះ $\lim\limits_{x \to +\infty} f(x) = \lambda$ ។ ( $\lambda$ ជាចំនួនពិត ) ។

៤/ បើ f និង g ជាអនុគមន៍ពីរ ហើយ A ជាចំនួនពិតមួយដែល

$\forall x \geq A : f(x) \leq g(x)$ និង $\lim\limits_{x \to +\infty} f(x) = \lambda$ , $\lim\limits_{x \to +\infty} g(x) = \lambda'$

នោះ $\lambda \leq \lambda'$ ។ ( $\lambda$ និង $\lambda'$ ជាចំនួនពិត ) ។

ឧទាហរណ៍ គេឲ្យ $f$ ជាអនុគមន៍ដែល $f(x)=\sqrt{x}(\sqrt{x+1}-\sqrt{x})$

គណនាលីមីត $\lim\limits_{x\to+\infty} f(x)$ ។

គេមាន $f(x)=\sqrt{x}(\sqrt{x+1}-\sqrt{x})=\dfrac{\sqrt{x}}{\sqrt{x+1}+\sqrt{x}}$

ដោយគ្រប់ $x>0$ គេមាន $\sqrt{x+1}>\sqrt{x}$

នោះគេទាញ $2\sqrt{x}<\sqrt{x+1}+\sqrt{x}<2\sqrt{x+1}$

ឬ $\dfrac{1}{2\sqrt{x+1}}<\dfrac{1}{\sqrt{x+1}+\sqrt{x}}<\dfrac{1}{2\sqrt{x}}$

ឬ $\dfrac{\sqrt{x}}{2\sqrt{x+1}}<\dfrac{\sqrt{x}}{\sqrt{x+1}+\sqrt{x}}<\dfrac{1}{2}$ នោះ $\dfrac{1}{2\sqrt{x+1}}<f(x)<\dfrac{1}{2}$

ដោយ $\lim\limits_{x\to+\infty}\dfrac{\sqrt{x}}{2\sqrt{x+1}}=\dfrac{1}{2}\lim\limits_{x\to+\infty}\dfrac{1}{\sqrt{1+\dfrac{1}{x}}}=\dfrac{1}{2}$

ដូចនេះ $\lim\limits_{x\to+\infty}\sqrt{x}(\sqrt{x+1}-\sqrt{x})=\dfrac{1}{2}$ ។

# ៧-លីមីតរាងមិនកំណត់

## ក/លីមីតដែលមានរាងមិនកំណត់ $\frac{0}{0}$

**វិធាន ៖** ដើម្បីគណនាលីមីតដែលមានរាងមិនកំណត់ $\frac{0}{0}$ គេត្រូវបំបែកភាគយក និង ភាគបែង ជាផលគុណកត្តា ហើយសម្រួលកត្តារួមចោល រួគណនាលីមីតនៃកន្សោមថ្មី។

ឧទាហរណ៍ គេឲ្យអនុគមន៍ $f$ ដែល $f(x)=\frac{2\sin^2 x-3\sin x+1}{\cos^2 x}$

គណនាលីមីត $\lim\limits_{x\to\frac{\pi}{2}} f(x)$ ?

គេមាន $f(x)=\frac{2\sin^2 x-3\sin x+1}{\cos^2 x}$

$$=\frac{(2\sin^2 x-2\sin x)-(\sin x-1)}{1-\sin^2 x}$$

$$=\frac{(\sin x-1)(2\sin x-1)}{(1-\sin x)(1+\sin x)}=\frac{1-2\sin x}{1+\sin x}$$

គេបាន $\lim\limits_{x\to\frac{\pi}{2}} f(x)=\lim\limits_{x\to\frac{\pi}{2}}\frac{1-2\sin x}{1+\sin x}=\frac{1-2}{1+1}=-\frac{1}{2}$ ។

## ខ/លីមីតដែលមានរាងមិនកំណត់ $\frac{\infty}{\infty}$

វិធាន ៖ ដើម្បីគណនាលីមីតរាងមិនកំនត់ $\frac{\infty}{\infty}$ គេត្រូវដាក់តួដែលមានដឺក្រេធំជាងគេនៅភាគយក និង ភាគបែងជាកត្តារួមសិន ហើសម្រួលកត្តារួមចោល រួចគណនាលីមីតនៃកន្សោមថ្មី ។

ឧទាហរណ៍ គេមានអនុគមន៍ $f$ កំណត់ដោយ ៖

$f(x)=\frac{\sqrt{4x^2+1}+7x+2}{3x+1}$ គណនាលីមីត $\lim\limits_{x\to+\infty} f(x)$ ។

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}\frac{\sqrt{4x^2+1}+7x+2}{3x+1}$$

$$=\lim_{x\to+\infty}\frac{\sqrt{x^2(4+\frac{1}{x^2})}+x(7+\frac{2}{x})}{x(3+\frac{1}{x})}=\lim_{x\to+\infty}\frac{x(\sqrt{4+\frac{1}{x^2}}+7+\frac{2}{x})}{x(3+\frac{1}{x})}$$

$$=\lim_{x\to+\infty}\frac{\sqrt{4+\frac{1}{x^2}}+7+\frac{2}{x}}{3+\frac{1}{x}}=\frac{2+7}{3}=3$$

ដូចនេះ $\lim\limits_{x\to+\infty} f(x)=3$ ។

## គ/លីមីតដែលមានរាងមិនកំណត់ $+\infty-\infty$

**វិធាន** ៖ ដើម្បីគណនាលីមីតរាងមិនកំនត់ $+\infty-\infty$ គេត្រូវដាក់តួដែលមានដឺក្រេធំជាងគេ ជាកត្តារួមសិន ហើសម្រួលកត្តារួមចោល រួចគណនាលីមីតនៃកន្សោមថ្មី ។

ឧទាហរណ៍ គេមាន $f(x)=\sqrt{x^2+5x}-\sqrt{x^2-3x+1}$

គណនាលីមីត $\lim\limits_{x\to+\infty} f(x)$ ។

មាន $f(x)=\sqrt{x^2+5x}-\sqrt{x^2-3x+1}$

$$=\frac{\sqrt{(x^2+5x)^2}-\sqrt{(x^2-3x+1)^2}}{\sqrt{x^2+5x}+\sqrt{x^2-3x+1}}$$

$$=\frac{x^2+5x-x^2+3x-1}{\sqrt{x^2(1+\frac{5}{x})}+\sqrt{x^2(1-\frac{3}{x}+\frac{1}{x^2})}}$$

$$=\frac{x(8-\frac{1}{x})}{x(\sqrt{1+\frac{5}{x}}+\sqrt{1-\frac{3}{x}+\frac{1}{x^2}})}=\frac{8-\frac{1}{x}}{\sqrt{1+\frac{5}{x}}+\sqrt{1-\frac{3}{x}+\frac{1}{x^2}}}$$

ដូចនេះ $\lim\limits_{x\to+\infty} f(x)=\frac{8}{1+1}=4$ ។

# លំហាត់អនុវត្តន៍ ៖

១-គណនាលីមីតខាងក្រោម ៖

ក/ $\lim\limits_{x\to\infty}\frac{4x+1}{2x+3}$

ខ/ $\lim\limits_{x\to\infty}\frac{8x+7}{12x-5}$

គ/ $\lim\limits_{x\to+\infty}\frac{e^x+2x-1}{2e^x+1}$

ឃ/ $\lim\limits_{x\to-\infty}\frac{e^x+4x-1}{e^x+2x+3}$

ង/ $\lim\limits_{x\to+\infty}\ln\frac{(2x+1)^2}{2x^2+3x}$

ច/ $\lim\limits_{x\to+\infty}\frac{(4e^x+1)^2}{(2e^x+1)(e^x+x)}$

២-រកតម្លៃ **a** និង **b** ដែលបំពេញលក្ខខណ្ឌខាងក្រោម ៖

ក/ $\lim\limits_{x\to+\infty}(\sqrt{x^2+ax}-bx-1)=3$

ខ/ $\lim\limits_{x\to+\infty}\frac{(a-1)x^2+2bx+3}{ax+b}=4$

គ/ $\lim\limits_{x\to+\infty}(\sqrt[3]{x^3+ax^2}-\sqrt[3]{bx^3-5x^2+1})=2$

៣-គេឲ្យពហុធា $P(x)=ax^2+bx+c$ ដែល $a,b,c\in IR$

កំណត់លេខមេគុណ $a,b,c$ ដោយដឹងថា ៖

$\lim\limits_{x\to\infty}\frac{P(x)}{x^2+1}=2$ (i) និង $\lim\limits_{x\to1}\frac{P(x)}{x^2-1}=2$ (ii)

# ៨-លីមីតនៃអនុគមន៍ត្រីកោណមាត្រ

ទ្រឹស្តីបទ ៖ បើ x ជារង្វាស់មុំ ឬ ធ្នូគិតជារ៉ាដ្យង់នោះគេបាន ៖

1/ $\lim\limits_{x\to 0}\frac{\sin x}{x}=1$ 2/ $\lim\limits_{x\to 0}\frac{1-\cos x}{x}=0$

3/ $\lim\limits_{x\to 0}\frac{\tan x}{x}=1$

*សម្រាយបញ្ជាក់* ៖

តាង $\varphi$ ជាមុំគិតជារ៉ាដ្យង់ ដែល $0<\varphi<\frac{\pi}{2}$

តាង $S_{OAT}$ , $S_{\overset{\frown}{OAP}}$ និង $S_{OAP}$

រៀងគ្នាជាផ្ទៃក្រឡានៃត្រីកោណ $OAT$

ផ្ទៃក្រឡាចំរៀកថាស $O\overset{\frown}{AP}$

និង ផ្ទៃក្រឡាត្រីកោណ $OAP$ ។

តាមរូបខាងលើ




គេមាន $S_{OAT}\geq S_{O\overset{\frown}{AP}}\geq S_{OAP}$

ដោយ $S_{OAT}=\frac{1}{2}\times 1\times\tan\varphi$ , $S_{\overset{\frown}{OAP}}=\frac{1}{2}\times 1^2\times\varphi$

និង $S_{OAP}=\frac{1}{2}\sin\theta$ នោះគេបាន $\frac{1}{2}\tan\varphi\geq\frac{1}{2}\varphi\geq\frac{1}{2}\sin\varphi$

ឬ $\tan\varphi\geq\varphi\geq\sin\varphi$ ដោយ $\tan\varphi=\frac{\sin\varphi}{\cos\varphi}$ នោះ $\frac{\sin\varphi}{\cos\varphi}\geq\varphi\geq\sin\varphi$

គេទាញ $\cos\varphi\leq\frac{\sin\varphi}{\varphi}\leq 1$ ។

បើ $-\frac{\pi}{2}<\varphi<0$ នោះ $0<-\varphi<\frac{\pi}{2}$ នោះវិសមភាពខាងលើទៅជា

$\cos(-\varphi)\leq\frac{\sin(-\varphi)}{-\varphi}\leq 1$ ឬ $\cos\varphi\leq\frac{\sin\varphi}{\varphi}\leq 1$

ហេតុនេះគេបាន $\cos\varphi\leq\frac{\sin\varphi}{\varphi}\leq 1$ ចំពោះគ្រប់ $\varphi\in(-\frac{\pi}{2},0)\cup(0,\frac{\pi}{2})$

ដោយ $\lim\limits_{\varphi\to 0}\cos\varphi=1$ នោះ $\lim\limits_{x\to 0}\frac{\sin\varphi}{\varphi}=1$ ។

ដោយជំនួស $\varphi$ ជា $x$ នោះគេបាន $\lim\limits_{x\to 0}\frac{\sin x}{x}=1$ ពិត ។

ម្យ៉ាងទៀត $\lim\limits_{x\to 0}\frac{1-\cos x}{x}=\lim\limits_{x\to 0}\frac{(1-\cos x)(1+\cos x)}{x(1+\cos x)}$

$$=\lim_{x\to 0}\frac{\sin x}{x}.\frac{\sin x}{1+\cos x}=1\times 0=0$$

ដូចនេះ $\lim_{x\to0}\frac{1-\cos x}{x}=0$ ពិត ។

តាមរូបមន្ត $\tan x=\frac{\sin x}{x}$

គេបាន $\lim_{x\to0}\frac{\tan x}{x}=\lim_{x\to0}\frac{\sin x}{x}.\frac{1}{\cos x}=1\times1=1$

ដូចនេះ $\lim_{x\to0}\frac{\tan x}{x}=1$ ។

*សម្គាល់* ៖

1/ $\lim_{x\to0}\frac{x}{\sin x}=1$

2/ $\lim_{x\to0}\frac{x}{\tan x}=1$

ឧទាហរណ៍ ៖ គណនាលីមីត

1/ $\lim_{x\to0}\frac{1-\cos x+\sin x}{x}=\lim_{x\to0}\frac{1-\cos x}{x}+\lim_{x\to0}\frac{\sin x}{x}=0+1=1$

2/ $\lim_{x\to0}\frac{1-\cos x}{x^2}=\lim_{x\to0}\frac{2\sin^2\frac{x}{2}}{x^2}=\frac{1}{2}\lim_{x\to0}\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\right)^2=\frac{1}{2}\times1^2=\frac{1}{2}$

3/ $\lim_{x\to0}\frac{x+\tan x}{x+\tan 3x}=\lim_{x\to0}\frac{1+\frac{\tan x}{x}}{1+\frac{\tan 3x}{3x}.3}=\frac{1+1}{1+3}=\frac{1}{2}$ ។

# លំហាត់អនុវត្តន៍ ៖

១-គណនាលីមីតខាងក្រោម ៖

1/ $\lim_{x\to 0}\frac{\sin 2x\sin 3x}{x^2}$

2/ $\lim_{x\to 0}\frac{\sin x+\sin 2x}{x}$

3/ $\lim_{x\to 0}\frac{\sin 4x}{\sin 6x}$

4/ $\lim_{x\to 0}\frac{3x+\sin x}{x+\sin x}$

5/ $\lim_{x\to 0}\frac{\sin x\sin 3x}{\sin^2 2x}$

6/ $\lim_{x\to 0}\frac{2x-\tan x}{x+\tan x}$

7/ $\lim_{x\to 0}\frac{\sin^2 2x}{\sin x\sin 6x}$

8/ $\lim_{x\to 0}\frac{x+3\sin x}{\sin 2x}$

9/ $\lim_{x\to 0}\frac{\sin 3x}{x+\sin 2x}$

10/ $\lim_{x\to 0}\frac{1-\cos 2x}{x^2}$

11/ $\lim_{x\to 0}\frac{x^2-\sin^2 x}{x^2-x\sin x}$

12/ $\lim_{x\to 0}\frac{x}{x+\tan x}$

13/ $\lim_{x\to 0}\frac{\sqrt{1+\sin x}-\sqrt{1-\sin x}}{\tan x}$

14/ $\lim_{x\to 0}\frac{\sqrt{2}-\sqrt{1+\cos x}}{x^2}$

15/ $\lim_{x\to 0}\frac{1-\cos x\cos 3x}{x^2}$

16/ $\lim_{x\to 0}\frac{1-\cos x}{1-\sqrt{\cos 2x}}$

17/ $\lim_{x\to 0}\frac{1-\cos x\cos 2x\cos 3x}{x^2}$

18/ $\lim_{x\to 0}\frac{x^2+\sin^2 x}{1-\cos 2x}$

២-កំណត់តម្លៃ a ដើម្បីបំពេញលក្ខខណ្ឌលីមីតខាងក្រោម ៖

1/ $\lim_{x\to 0}\frac{1-\cos ax}{x^2}=8$

2/ $\lim_{x\to 0}\frac{\sin ax}{x}=5$

3/ $\lim_{x\to 0}\frac{\sin ax+\sin(a+1)x}{x}=3$

4/ $\lim_{x\to 0}\frac{2-2\cos ax}{x^2}=4$

5/ $\lim_{x\to 0}\frac{\sin(a+1)x+\sin(a-1)x}{x}=6$

៣-កំណត់តម្លៃ a និង b ដើម្បីឲ្យ $\lim_{x\to 0}\frac{a+b\cos x}{x^2}=1$ ។

៤-គណនាលីមីតខាងក្រោម ៖

1/ $\lim_{x\to 1}\frac{\sin \pi x}{x^2-1}$

2/ $\lim_{x\to 1}(1-x^2)\tan\frac{\pi x}{2}$

3/ $\lim_{x\to \pi}\frac{1-\cos 2x}{(\pi-x)^2}$

4/ $\lim_{x\to \frac{\pi}{2}}\frac{\cos x}{\pi-2x}$

5/ $\lim_{x\to 1}\frac{1-\cos 2\pi x}{(1-x)^2}$

6/ $\lim_{x\to 2}\frac{1-\sin\frac{\pi x}{4}}{(2-x)^2}$

៥-កំណត់ ដើម្បីឲ្យបាន $\lim_{x\to 0}\frac{1+a\cos x+\cos 2x}{x^2}=b$

( a និង b ជាពីរចំនួនពិត ) ។

## ៩-លីមីតនៃអនុគមន៍អិចស្ប៉ូណង់ស្យែល

*រូបមន្ត ៖*

1/ $\lim_{x \to +\infty} e^x = +\infty$

2/ $\lim_{x \to -\infty} e^x = 0$

3/ $\lim_{x \to +\infty} \frac{e^x}{x} = +\infty$

4/ $\lim_{x \to +\infty} \frac{x}{e^x} = 0$

5/ $\lim_{x \to +\infty} \frac{e^x}{x^n} = +\infty$

6/ $\lim_{x \to +\infty} \frac{x^n}{e^x} = +\infty$

( ដែល **n** ជាចំនួនពិតវិជ្ជមាន ) ។

## ១០-លីមីតនៃអនុគមន៍លោការីតនេពែ

*រូបមន្ត ៖*

1/ $\lim_{x \to +\infty} \ln x = +\infty$

2/ $\lim_{x \to 0^+} \ln x = -\infty$

3/ $\lim_{x \to +\infty} \frac{\ln x}{x} = 0$

4/ $\lim_{x \to 0^+} x \ln x = 0$

5/ $\lim_{x \to +\infty} \frac{\ln x}{x^n} = 0$

6/ $\lim_{x \to 0^+} x^n \ln x = 0$

( ដែល **n** ជាចំនួនពិតវិជ្ជមាន )។

## *លំហាត់គំរូ*

គណនាលីមីតខាងក្រោម ៖

1/ $\lim\limits_{x\to+\infty}\frac{6e^x+x}{2e^x+1}=\lim\limits_{x\to+\infty}\frac{e^x(6+\frac{x}{e^x})}{e^x(2+\frac{1}{e^x})}=\lim\limits_{x\to+\infty}\frac{6+\frac{x}{e^x}}{2+\frac{1}{e^x}}=\frac{6}{2}=3$

2/ $\lim\limits_{x\to0^+}\frac{x^2\ln x+\sin x}{x}=\lim\limits_{x\to0^+}(x\ln x)+\lim\limits_{x\to0^+}\frac{\sin x}{x}=0+1=1$

3/ $\lim\limits_{x\to+\infty}\frac{2x-\ln x}{x+\ln x}=\lim\limits_{x\to+\infty}\frac{x(2-\frac{\ln x}{x})}{x(1+\frac{\ln x}{x})}=\lim\limits_{x\to+\infty}\frac{2-\frac{\ln x}{x}}{1+\frac{\ln x}{x}}=\frac{2}{1}=2$

4/ $\lim\limits_{x\to-\infty}\frac{e^{2x}+3}{e^x+1}=\frac{\lim\limits_{x\to-\infty}(e^{2x}+3)}{\lim\limits_{x\to-\infty}(e^x+1)}=\frac{0+3}{0+1}=3$ ព្រោះ $\lim\limits_{x\to-\infty}e^x=0$ ។

5/ $\lim\limits_{x\to+\infty}[2x-\ln(2e^{2x}+1)]=\lim\limits_{x\to+\infty}[\ln(e^{2x})-\ln(2e^{2x}+1)]$

$$=\lim_{x\to+\infty}[\ln(\frac{e^{2x}}{2e^{2x}+1})]$$

$$=\lim_{x\to+\infty}\ln(\frac{1}{2+\frac{1}{e^{2x}}})=\ln\frac{1}{2}$$

# លំហាត់អនុវត្តន៍ ៖

១-គណនាលីមីតខាងក្រោម ៖

1/ $\lim\limits_{x\to+\infty}\frac{2e^x+3}{e^x+1}$

2/ $\lim\limits_{x\to+\infty}\frac{4e^x+1}{2e^x-3}$

3/ $\lim\limits_{x\to-\infty}\frac{2e^x-x+1}{e^x+2x+3}$

4/ $\lim\limits_{x\to-\infty}\frac{e^x+x}{3e^x+2x-1}$

5/ $\lim\limits_{x\to+\infty}\frac{e^{2x}}{(2e^x+1)(e^x-3)}$

6/ $\lim\limits_{x\to+\infty}\frac{e^x+e^{-x}}{e^x+x}$

២-គណនាលីមីតខាងក្រោម ៖

1/ $\lim\limits_{x\to0^+}(1+2x-x\ln x)$

2/ $\lim\limits_{x\to0^+}\frac{\frac{1}{x}+\ln x}{\cot x}$

3/ $\lim\limits_{x\to0^+}(\frac{1}{x}+\ln x)\sin x$

4/ $\lim\limits_{x\to0^+}\frac{x^x-1}{x\ln x}$

5/ $\lim\limits_{x\to+\infty}\frac{1+\ln x}{1-\ln x}$

6/ $\lim\limits_{x\to+\infty}\frac{2x+1-\ln x}{4x+1}$

7/ $\lim\limits_{x\to+\infty}\frac{2x-\ln x}{x+\ln x}$

8/ $\lim\limits_{x\to+\infty}\frac{1+xe^x}{1+2xe^x}$

9/ $\lim\limits_{x\to+\infty}\frac{1}{x}(2x+\ln x)$

10/ $\lim\limits_{x\to+\infty}[\ln x-\ln(2x+1)]$

## ១១-ការគណនាលីមីតរាងផ្សេងៗទៀតគួយល់ដឹង

### ក-ការគណនាលីមីតដោយប្រើរូបមន្ត ៖

$$1/\ \lim_{x\to 0}\frac{e^x-1}{x}=1$$

$$2/\ \lim_{x\to 0}\frac{a^x-1}{x}=\ln a \quad \text{ដែល } a>0 \text{ និង } a\neq 1 \text{ ។}$$

**លំហាត់គំរូ** គណនាលីមីតខាងក្រោម ៖

$$1/\ \lim_{x\to 0}\frac{e^{\sin x}-1}{x}=\lim_{x\to 0}\frac{e^{\sin x}-1}{\sin x}\times\frac{\sin x}{x}=1\times 1=1$$

$$2/\ \lim_{x\to 0}\frac{e^{x^2}-\cos 2x}{x^2}=\lim_{x\to 0}\frac{e^{x^2}-(1-2\sin^2 x)}{x^2}$$

$$=\lim_{x\to 0}\frac{e^{x^2}-1}{x^2}+2\lim_{x\to 0}\left(\frac{\sin x}{x}\right)^2$$

$$=1+2\times 1^2=3$$

$$3/\ \lim_{x\to 0}\frac{a^x-b^x}{x}=\lim_{x\to 0}\frac{(a^x-1)-(b^x-1)}{x}$$

$$=\lim_{x\to 0}\frac{a^x-1}{x}-\lim_{x\to 0}\frac{b^x-1}{x}$$

$$=\ln a-\ln b=\ln\frac{a}{b}$$

## ខ-ការគណនាលីមីតដោយប្រើរូបមន្ត ៖

$$\lim_{x\to 0}\frac{\ln(1+x)}{x}=1$$

**លំហាត់គំរូ** គណនាលីមីតខាងក្រោម ៖

1/ $\lim\limits_{x\to 0}\frac{\ln(1+\tan 2x)}{x}=\lim\limits_{x\to 0}\frac{\ln(1+\tan 2x)}{\tan 2x}.\frac{\tan 2x}{2x}.2=1\times 1\times 2=2$

2/ $\lim\limits_{x\to 0}\frac{\ln(\cos 2x)}{x^2}=\lim\limits_{x\to 0}\frac{\ln(1-2\sin^2 x)}{x^2}$

$$=\lim_{x\to 0}\frac{\ln(1-2\sin^2 x)}{(-2\sin^2 x)}\times\frac{\sin^2 x}{x^2}\times(-2)=-2$$

3/ $\lim\limits_{x\to 0}\frac{\ln(1+4x-x^2)}{x}=\lim\limits_{x\to 0}\frac{\ln(1+4x-x^2)}{4x-x^2}\times\frac{4x-x^2}{x}$

$$=\lim_{x\to 0}\frac{\ln(1+4x-x^2)}{4x-x^2}.(4-x)=1\times 4=4$$

4/ $\lim\limits_{x\to 0}\frac{\ln(3-2e^x)}{x}=\lim\limits_{x\to 0}\frac{\ln(1+2(1-e^x)]}{2(1-e^x)}\times\frac{-2(e^x-1)}{x}=-2$

5/ $\lim\limits_{x\to 0}\frac{\ln[(1+ax)(1+bx)]}{x}=\lim\limits_{x\to 0}\frac{\ln(1+ax)+\ln(1+bx)}{x}$

$=\lim\limits_{x\to 0}\frac{\ln(1+ax)}{ax}.a+\lim\limits_{x\to 0}\frac{\ln(1+bx)}{bx}.b=a+b$ ។

## គ-ការគណនាលីមីតដោយប្រើរូបមន្ត ៖

1/ $\lim_{x\to 0}(1+x)^{\frac{1}{x}} = e$

2/ $\lim_{x\to +\infty}\left(1+\frac{1}{x}\right)^{x} = e$ ដែល $e = 2.71828...$

**លំហាត់គំរូ** គណនាលីមីតខាងក្រោម ៖

1/ $$\lim_{x\to 0}\left(1+\frac{x}{2}\right)^{\frac{1}{x}} = \lim_{x\to 0}\left[\left(1+\frac{x}{2}\right)^{\frac{1}{x/2}}\right]^{\frac{1}{2}} = e^{\frac{1}{2}} = \sqrt{e}$$

2/ $$\lim_{x\to 0}\left(1+\sin\frac{x}{2}\right)^{\frac{1}{x}} = \lim_{x\to 0}\left[\left(1+\sin\frac{x}{2}\right)^{\frac{1}{\sin\frac{x}{2}}}\right]^{\frac{\sin\frac{x}{2}}{\frac{x}{2}}\cdot\frac{1}{2}} = e^{\frac{1}{2}} = \sqrt{e}$$

3/ $$\lim_{x\to +\infty}\left(1+\frac{2}{x}\right)^{x} = \left[\left(1+\frac{2}{x}\right)^{\frac{x}{2}}\right]^{2} = e^{2}$$

4/ $$\lim_{x\to +\infty}\left(\frac{x-1}{x+1}\right)^{x} = \lim_{x\to +\infty}\left[1+\left(\frac{-2}{x+1}\right)^{\frac{x+1}{-2}}\right]^{\frac{-2x}{x+1}} = e^{-2} = \frac{1}{e^{2}}$$ ។

# លំហាត់អនុវត្តន៍ ៖

## ១-គណនាលីមីតនៃអនុគមន៍ខាងក្រោម ៖

1/ $\lim\limits_{x\to 0}\dfrac{e^{x}+e^{2x}-2}{x}$

2/ $\lim\limits_{x\to 0}\dfrac{e^{\sin x}-e^{-\sin x}}{x}$

3/ $\lim\limits_{x\to 0}\dfrac{e^{\sin^2 x}-\cos 4x}{x^2}$

4/ $\lim\limits_{x\to 0}\dfrac{1-e^{1-\cos 2x}}{x^2}$

5/ $\lim\limits_{x\to 0}\dfrac{e^{ax^2}-e^{bx^2}}{2}$

6/ $\lim\limits_{x\to 0}\dfrac{e^{x^2-2x}-e^{x^2+2x}}{x}$

7/ $\lim\limits_{x\to 0}\dfrac{e^{-2x}+e^{2x}-2}{x^2}$

8/ $\lim\limits_{x\to 0}\dfrac{e^{\tan^2 x}-e^{\sin^2 x}}{1+x\sin 2x-\cos 2x}$

9/ $\lim\limits_{x\to 0}\dfrac{\sqrt{2}-\sqrt{1+e^{x^2}}}{\sin^2 x}$

10/ $\lim\limits_{x\to 0}\dfrac{\sqrt[3]{2-e^{x^2}}-1}{x^2}$

## ២-គណនាលីមីតខាងក្រោម ៖

1/ $\lim\limits_{x\to 0}\dfrac{\ln(1+2\tan 3x)}{\sin x}$

2/ $\lim\limits_{x\to 0}\dfrac{\ln(2-e^{\sin^2 x})}{x\tan x}$

3/ $\lim\limits_{x\to 0}\dfrac{\ln(\cos x)+\ln(\cos 2x)}{x^2}$

4/ $\lim\limits_{x\to 1}\dfrac{\ln(x^3-3x+3)}{(x-1)^2}$

## ៣-គណនាលីមីតខាងក្រោម ៖

1/ $\lim\limits_{x\to 0}\left(\frac{x^2-x+1}{x^2+x+}\right)^{\frac{2}{x}}$

2/ $\lim\limits_{x\to 0}\left(\frac{1-\sin x}{1+\sin x}\right)^{\frac{1}{x}}$

3/ $\lim\limits_{x\to 0}\left(\frac{\sin x}{x}\right)^{\frac{x}{x-\sin x}}$

4/ $\lim\limits_{x\to 0}\left(\frac{2x^2+x+3}{x+3}\right)^{\frac{1}{\sin x}}$

5/ $\lim\limits_{x\to 0}\left(\cos x\right)^{\frac{1}{x^2}}$

6/ $\lim\limits_{x\to 0}\left(\frac{1+\tan x}{1+\sin x}\right)^{\frac{1}{x^3}}$

7/ $\lim\limits_{x\to 1}\left(\frac{x^2+x+3}{x+4}\right)^{\frac{1}{x-1}}$

8/ $\lim\limits_{x\to 2}\left(\frac{2x+1}{x^2+1}\right)^{\frac{x}{x-2}}$

9/ $\lim\limits_{x\to \frac{\pi}{4}}\left(\tan x\right)^{\tan 2x}$

10/ $\lim\limits_{x\to \frac{\pi}{2}}(\sin x)^{\frac{1}{(\pi-x)^2}}$

11/ $\lim\limits_{x\to 1}\left(\sin\frac{\pi x}{2}\right)^{\frac{x}{(1-x)^2}}$

12/ $\lim\limits_{x\to \infty}\left(\frac{x-1}{x+1}\right)^{x}$

13/ $\lim\limits_{x\to \infty}\left(\frac{x^2+3x+1}{x^2-3x+4}\right)^{x}$

14/ $\lim\limits_{x\to \infty}\left(\frac{e^x+x}{e^x+1}\right)^{e^x}$

ជំពូកទី២

# ភាពជាប់នៃអនុគមន៍

## ១-សញ្ញាណនៃអនុគមន៍ជាប់

កាលណាគេគូសក្រាបនៃធនុគមន៍ $y = f(x)$ លើចន្លោះ $I$ មួយនៃដែនកំណត់ ដោយមិនលើកខ្មៅដៃ នោះគេបានគំនូស ជាខ្សែកោងជាប់ គេថាអនុគមន៍ $f$ ជាអនុគមន៍ជាប់ត្រង់គ្រប់ចំណុចនៃចន្លោះ $I$ ។



## ២-ភាពជាប់ត្រង់មួយចំណុច

**និយមន័យ** អនុគមន៍ $y = f(x)$ ជាអនុគមន៍ជាប់ត្រង់ចំណុច $x = a$ កាលណា $f$ បំពេញលក្ខខណ្ឌទាំងបីខាងក្រោម ៖

1/ $f$ កំណត់ចំពោះ $x = a$

2/ $f$ មានលីមីតកាលណា $x$ ខិតជិត $a$

3/ $\lim_{x \to a} f(x) = f(a)$ ។

ឧទាហរណ៍១ គេមានអនុគមន៍ $f$ កំណត់ដោយ $f(x) = \sqrt{x^3 + 1}$

តើអនុគមន៍ $f$ ជាប់ត្រង់ចំណុច $x = 2$ ឬទេ ?

ចំពោះ $x = 2$ គេបាន $f(2) = \sqrt{2^3 + 1} = \sqrt{9} = 3$ កំណត់

$$\lim_{x \to 2} f(x) = \lim_{x \to 2} \sqrt{x^3 + 1} = \sqrt{2^3 + 1} = 3$$

គេបាន $\lim_{x \to 2} f(x) = f(2) = 3$ ។

ដូចនេះ $f$ ជាអនុគមន៍ជាប់ត្រង់ចំណុច $x = 2$ ។

## ឧទាហរណ៍២

គេឲ្យអនុគមន៍ f កំណត់ដោយ ៖

$$f(x) = \begin{cases} \sqrt{x^2+2x+6} & \text{បើ} \quad x \geq 1 \\ \dfrac{2x-11}{x-2} & \text{បើ} \quad x < 1 \end{cases}$$

តើ f ជាអនុគមន៍ជាប់ត្រង់ $x = 1$ ឬទេ ?

ចំពោះ $x = 1$ គេបាន $f(2) = \sqrt{1^2+2+6} = \sqrt{9} = 3$ កំណត់

$$\lim_{x \to 1^+} f(x) = \lim_{x \to 1^+} \sqrt{x^2+2x+6} = \sqrt{1+2+6} = 3$$

$$\lim_{x \to 1^-} f(x) = \lim_{x \to 1^-} \frac{2x-5}{x-2} = \frac{2-5}{1-2} = 3$$

ដោយ $\lim_{x \to 1^-} f(x) = \lim_{x \to 1^+} f(x) = 3$

នោះ $\lim_{x \to 1} f(x) = f(1) = 3$ ។

ដូចនេះ f ជាអនុគមន៍ជាប់ត្រង់ចំណុច $x = 2$ ។

ឧទាហរណ៍៣

គេឲ្យអនុគមន៍ $f$ កំណត់ដោយ ៖

$$f(x)=\begin{cases}\dfrac{1-x}{1+x} & \text{បើ } x\geq 0\\ \dfrac{2\sqrt{x^2}-\sin x}{x} & \text{បើ } x<0\end{cases}$$

តើ $f$ ជាអនុគមន៍ជាប់ត្រង់ $x=0$ ឬទេ ?

ចំពោះ $x=0$ គេបាន $f(0)=\dfrac{1-0}{1+0}=1$ កំណត់

$$\lim_{x\to 0^+} f(x)=\lim_{x\to 0^+}\frac{1-x}{1+x}=1$$

$$\lim_{x\to 0^-} f(x)=\lim_{x\to 0^-}\frac{2\sqrt{x^2}-\sin x}{x}=\lim_{x\to 0^-}\frac{2|x|-\sin x}{x}$$

$$=\lim_{x\to 0^-}\frac{-2x-\sin x}{x}=\lim_{x\to 0^-}\left(-2-\frac{\sin x}{x}\right)=-3$$

ដោយ $\lim\limits_{x\to 0^-} f(x)\neq \lim\limits_{x\to 0^+} f(x)$ នោះ $\lim\limits_{x\to 0} f(x)$ គ្មានលីមីត ។

ដូចនេះ $f$ ជាអនុគមន៍ដាច់ត្រង់ចំណុច $x=0$ ។

ឧទាហរណ៍៤

គេឲ្យអនុគមន៍ $f$ កំណត់ដោយ ៖

$$f(x) = \begin{cases} \dfrac{2-2\cos 2ax}{x^2} & \text{បើ} \quad x \neq 0 \\ 9 & \text{បើ} \quad x = 0 \end{cases}$$

កំណត់ចំនួនពិត $a$ ដើម្បីឲ្យ $f$ ជាអនុគមន៍ជាប់ត្រង់ $x = 0$ ។

ចំពោះ $x = 0$ គេបាន $f(0) = 9$ កំណត់

$$\lim_{x\to 0} f(x) = \lim_{x\to 0} \frac{2-2\cos 2ax}{x^2}$$

$$= \lim_{x\to 0} \frac{4\sin^2 ax}{x^2} = 4a^2 \lim_{x\to 0}\left(\frac{\sin ax}{ax}\right)^2 = 4a^2$$

ដើម្បីឲ្យ $f$ ជាអនុគមន៍ជាប់ត្រង់ចំណុច $x = 0$ គេគ្រាន់តែឲ្យ

$\lim_{x\to 0} f(x) = f(0)$ ឬ $4a^2 = 9$ នោះ $a = \pm \dfrac{3}{2}$ ។

ដូចនេះ $a = \pm \dfrac{3}{2}$ ។

## ៣-លក្ខណៈភាពជាប់នៃអនុគមន៍

បើ f និង g ជាអនុគមន៍ជាប់ត្រង់ចំណុច $x=a$ នោះគេបាន ៖

1/ $f(x)+g(x)$ ជាអនុគមន៍ជាប់ត្រង់ ចំណុច $x=a$ ។

2/ $f(x)-g(x)$ ជាអនុគមន៍ជាប់ត្រង់ ចំណុច $x=a$ ។

3/ $f(x).g(x)$ ជាអនុគមន៍ជាប់ត្រង់ ចំណុច $x=a$ ។

4/ $\lambda f(x)$ ជាអនុគមន៍ជាប់ត្រង់ ចំណុច $x=a$ ។ ($\lambda$ ជាចំនួនពិត)

5/ $\frac{f(x)}{g(x)}$ ជាអនុគមន៍ជាប់ត្រង់ ចំណុច $x=a$ ដែល $g(a)\neq 0$ ។

## ៤-ភាពជាប់លើចន្លោះ

**និយមន័យ ៖**

1/អនុគមន៍ f ជាប់លើចន្លោះបើក (a,b) លុះត្រាតែ f ជាប់ចំពោះ

គ្រប់តម្លៃ x នៃចន្លោះបើកនោះ ។

2/អនុគមន៍ f ជាប់លើចន្លោះបិទ [a,b] លុះត្រាតែ f ជាប់លើ (a,b)

និងមានលីមីត $\lim_{x\to a^+} f(x)=f(a)$ និង $\lim_{x\to b^-} f(x)=f(b)$ ។

**ឧទាហរណ៍** គេមានអនុគមន៍ f កំណត់ដោយ ៖

$$f(x)=\begin{cases} 1+x\ln x & \text{បើ } x>0 \\ 1 & \text{បើ } x=0 \\ \dfrac{\sin\pi}{1-x} & \text{បើ } x<1 \\ \pi & \text{បើ } x=1 \end{cases}$$

ចូរសិក្សាភាពជាប់នៃអនុគមន៍ f លើចន្លោះ $[0,1]$ ។

យើងពិនិត្យឃើញថា f ជាអនុគមន៍ជាប់លើ $(0,1)$ ។

គេមាន $f(0)=1$ និង $f(1)=\pi$

ហើយ $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+}(1+x\ln x)=1=f(0)$

និង $\lim\limits_{x\to 1^-} f(x)=\lim\limits_{x\to 1^-}\dfrac{\sin\pi x}{1-x}$

តាង $1-x=t$ នោះ $x=1-t$

ហើយកាលណា $x\to 1^-$ នោះ $t\to 0^+$

$$\lim_{x\to 1^-} f(x)=\lim_{t\to 0^+}\frac{\sin(\pi-\pi t)}{t}=\lim_{t\to 0^+}\frac{\sin(\pi t)}{(\pi t)}.\pi=\pi=f(1)$$

ដូចនេះ អនុគមន៍ f ជាប់លើចន្លោះ $[0,1]$ ។

# ៥-ភាពជាប់នៃអនុគមន៍បណ្តាក់

អនុគមន៍ $g$ ជាប់ត្រង់ $x=a$ និងអនុគមន៍ $f$ ជាប់ត្រង់ $x=g(a)$ នោះអនុគមន៍បណ្តាក់ $(f\circ g)(x)=f[g(x)]$ ជាប់ត្រង់ $x=a$ ។

**ឧទាហរណ៍** គេឲ្យអនុគមន៍ $g$ កំណត់ដោយ $g(x)=\dfrac{4x}{x^2+1}$ និង $f(x)=\ln x$ ។

តើអនុគមន៍ $(f\circ g)(x)=f[g(x)]$ ជាប់ត្រង់ $x=1$ ដែរឬទេ ?

គេមាន $g(1)=\dfrac{4}{1^2+1}=2$

ហើយ $\lim\limits_{x\to1}g(x)=\lim\limits_{x\to1}\dfrac{4x}{x^2+1}=\dfrac{4}{1+1}=2=g(1)$ នោះ $g$ ជាអនុគមន៍ជាប់ត្រង់ $x=1$ ។

ហើយបើ $x=g(1)=2$ នោះ $f(2)=\ln 2$

និង $\lim\limits_{x\to2}f(x)=\lim\limits_{x\to2}\ln x=\ln=f(2)$ នោះ$f$ ជាអនុគមន៍ជាប់ត្រង់ $x=2$

សម្រាយខាងលើបញ្ជាក់ថា $(f\circ g)(x)=f[g(x)]$ ជាប់ត្រង់ $x=1$ ។

# ៦-អនុគមន៍បន្លាយតាមភាពជាប់

បើ $f$ ជាអនុគមន៍មិនកំណត់ត្រង់ $x=a$ និងមានលីមីត $\lim\limits_{x\to a} f(x)=\lambda$ នោះអនុគមន៍បន្លាយនៃ $f$ តាមភាពជាប់ត្រង់ $x=a$ កំណត់ដោយ ៖

$$g(x)=\begin{cases} f(x) & \text{បើ } x\neq a \\ \lambda & \text{បើ } x=a \end{cases}$$

ឧទាហរណ៍១ គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{\tan x-\sin x}{x^3}$

រកអនុគមន៍បន្លាយតាមភាពជាប់នៃ $f$ ត្រង់ $x=0$ ។

គេមាន $\lim\limits_{x\to 0} f(x)=\lim\limits_{x\to 0}\dfrac{\tan x-\sin x}{x^3}$ ដោយ $\sin x=\tan x.\cos x$

$$=\lim_{x\to 0}\frac{\tan x-\sin x.\tan x}{x^3}=\lim_{x\to 0}\frac{\tan x(1-\cos x)}{x^3}$$

$$=\lim_{x\to 0}\frac{\tan x}{x}.\frac{\sin^2\frac{x}{2}}{\left(\frac{x}{2}\right)^2}.\frac{1}{2}=\frac{1}{2}$$

ដូចនេះ $g(x)=\begin{cases} \dfrac{\tan x-\sin x}{x^3} & \text{បើ } x\neq 0 \\ \dfrac{1}{2} & \text{បើ } x=0 \end{cases}$

ឧទាហរណ៍២

គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{\sin x+x^2\ln|x|}{x}$ ដែល $x\neq 0$ ។

តើ $f$ អាចមានអនុគមន៍បន្លាយតាមភាពជាប់ ត្រង់ $x=0$ ឬទេ ?

បើមានចូរកំណត់រកអនុគមន៍នោះ ។

គេមាន $\lim\limits_{x\to 0} f(x)=\lim\limits_{x\to 0}\dfrac{\sin x+x^2\ln|x|}{x}$

$$=\lim_{x\to 0}\left(\frac{\sin x}{x}+x\ln|x|\right)$$

$$=\lim_{x\to 0}\frac{\sin x}{x}+\lim_{x\to 0}(x\ln|x|)=1+0=1$$

ដូចនេះ $f$ អាចមានអនុគមន៍បន្លាយតាមភាពជាប ត្រង់ $x=0$ ហើយបើ

$g$ ជាបន្លាយនៃអនុគមន៍ $f$ តាមភាពជាប់ត្រង់ $x=0$ នោះគេបាន ៖

$$g(x)=\begin{cases}\dfrac{\sin x+x^2\ln|x|}{x} & \text{បើ } x\neq 0\\ 1 & \text{បើ } x=0\end{cases}$$

## ៧-ទ្រឹស្តីបទតម្លៃកណ្តាល

*ទ្រឹស្តីបទ* ៖ បើអនុគមន៍ **f** ជាប់លើចន្លោះបិទ **[a,b]** និង **k** ជាចំនួនមួយនៅចន្លោះ **f(a)** និង **f(b)** នោះមានចំនួនពិត **c** មួយយ៉ាងតិចក្នុងចន្លោះបិទ **[a,b]** ដែល $f(c) = k$ ។

*សម្រាយបញ្ជាក់* ៖




អនុគមន៍ **f** ជាប់ និង កើនដាច់ខាត លើចន្លោះបិទ**[a,b]** ។

**f** ជាអនុគមន៍កើនដាច់ខាត មានន័យថាមានពីរចំនួន $\alpha$ , $\beta$ នៃ**[a,b]**

ដែល $\alpha < \beta$ នាំឲ្យ $f(\alpha) < f(\beta)$ ។ ឲ្យចំនួន $k$ នៅចន្លោះ $f(a)$ និង $f(b)$

( $f(a) < k < f(b)$ ) និង $f$ ជាអនុគមន៍ជាប់ តាមទ្រឹស្តីបទបញ្ជាក់ថាមាន

ចំនួន $c$ នៅចន្លោះ $a$ និង $b$ ដែល $f(c) = k$ ។

ឧបមាថាមានចំនួន $c'$ មួយទៀតផ្សេងពី $c$ ដែល $f(c') = k$ នោះគេបាន

$f(c) = f(c')$ ដែលផ្ទុយពីសម្មតិកម្មដែលថា $f$ ជាងនុគមន៍កើនដាច់ខាត

ដូចនេះមានចំនួន $c$ តែមួយគត់ដែលផ្ទៀងផ្ទាត់ $f(c) = k$ មានន័យថា

សមីការ $f(x) = k$ មានចម្លើយតែមួយគត់ ។

***វិបាក*** ៖ បើអនុគមន៍ $f$ ជាប់ហើយកើនដាច់ខាត ឬ ចុះដាច់ខាតលើ

ចន្លោះបិទ $[a,b]$ នោះចំពោះគ្រប់ចំនួន $k$ នៅចន្លោះ $f(a)$ និង $f(b)$

សមីការ $f(x) = k$ មានចម្លើយតែមួយគត់នៅចន្លោះ $[a,b]$ ។

***សម្គាល់*** ៖ ទ្រឹស្តីបទតម្លៃកណ្តាលអាចប្រើបានចំពោះ $k = 0$ ជាពិសេស

បើ $f$ ជាអនុគមន៍ជាប់លើចន្លោះបិទ $[a,b]$ និង $f(a).f(b) < 0$ នោះ

មានចំនួន $c$ មួយយ៉ាងតិចនៃ $[a,b]$ ដែល $f(c) = 0$ ។

*ឧទាហរណ៍*

ស្រាយបញ្ជាក់ថាសមីការ $\mathbf{x\tan x = \cos x}$ យ៉ាងហោច

ណាស់មានឬសជាចំនួនពិតមួយនៅចន្លោះ $\left[0\,,\frac{\pi}{4}\right]$ ។

តាង $\mathbf{f(x) = x\tan x - \cos x}$

គេមាន $\mathbf{f(0) = 0 - 1 = -1 < 0}$

និង $\mathbf{f(\frac{\pi}{4}) = \frac{\pi}{4} - \frac{\sqrt{2}}{2} = \frac{\pi - 2\sqrt{2}}{4} = \frac{3.14 - 2\times 1.41}{4} = \frac{0.32}{4} = 0.80 > 0}$

គេបាន $\mathbf{f(0).f(\frac{\pi}{4}) < 0}$ នោះតាមទ្រឹស្តីបទតម្លៃកណ្តាលយ៉ាងហោច

ណាស់មានចំនួនពិត $\mathbf{c}$ មួយនៃចន្លោះ $\left[0\,,\frac{\pi}{4}\right]$ ដែល $\mathbf{f(c) = 0}$ ។

ដូចនេះថាសមីការ $\mathbf{x\tan x = \cos x}$ យ៉ាងហោចណាស់មានឬសជា

ចំនួនពិតមួយនៅចន្លោះ $\left[0\,,\frac{\pi}{4}\right]$ ។

## លំហាត់អនុវត្តន៍

1/គេមានអនុគមន៍ f កំណត់ដោយ ៖

$$f(x)=\begin{cases}\dfrac{\sin 2x-2\sin x}{x^3} & \text{បើ}\quad x\neq 0\\ -1 & \text{បើ}\quad x=0\end{cases}$$

ចូរសិក្សាភាពជាប់នៃអនុគមន៍ f ត្រង់ចំណុច $x=0$ ។

2/គេមានអនុគមន៍ f កំណត់ដោយ ៖

$$f(x)=\begin{cases}\dfrac{e^x+e^{-x}-2}{x^2} & \text{បើ}\quad x\neq 0\\ 1 & \text{បើ}\quad x=0\end{cases}$$

តើអនុគមន៍ f ជាប់ត្រង់ចំណុច $x=0$ ដែរឬទេ ?

3/គេមានអនុគមន៍ f កំណត់ដោយ ៖

$$f(x)=\begin{cases}\dfrac{\ln(1+2\sin^2 x)}{x^2} & \text{បើ}\quad x\neq 0\\ 2 & \text{បើ}\quad x=0\end{cases}$$

ចូរស្រាយថាអនុគមន៍ f ជាប់ត្រង់ចំណុច $x=0$ ។

4/គេមានអនុគមន៍ f កំណត់ដោយ ៖

$$f(x) = \begin{cases} \dfrac{1-\cos ax}{x^2} & \text{បើ } x \neq 0 \\ 8 & \text{បើ } x = 0 \end{cases}$$

ចូរកំណត់ចំនួនពិត a ដើម្បីឲ្យអនុគមន៍ f ជាប់ត្រង់ចំណុច $x=0$ ។

5/គេមានអនុគមន៍ f កំណត់ដោយ ៖

$$f(x) = \begin{cases} x^2+ax+2 & \text{បើ } x \leq 1 \\ (x+a)^2 & \text{បើ } x > 1 \end{cases}$$

ចូរកំណត់ចំនួនពិត a ដើម្បីឲ្យអនុគមន៍ f ជាប់ត្រង់ចំណុច $x=1$ ។

6/រកតម្លៃ A ដែលនាំឲ្យអនុគមន៍ f ជាប់គ្រប់តម្លៃ x ក្នុងករណីនីមួយៗ

ក/ $f(x) = \begin{cases} Ax-3 & \text{បើ } x < 2 \\ 3-x+2x^2 & \text{បើ } x \geq 2 \end{cases}$

ខ/ $f(x) = \begin{cases} 1-3x & \text{បើ } x < 4 \\ Ax^2+2x-3 & \text{បើ } x \geq 4 \end{cases}$

គ/ $f(x) = \begin{cases} x^2+Ax+2 & \text{បើ } x \leq 1 \\ \dfrac{\sin \pi x}{\pi - \pi x} & \text{បើ } x > 1 \end{cases}$

7/ចូររកអនុគមន៍បន្លាយនៃ $f$ តាមភាពជាប់ត្រង់ចំណុច $x = a$ ក្នុងករណីនីមួយៗដូចខាងក្រោម ៖

ក/ $f(x) = \dfrac{1 - \cos x \cos 2x}{x^2}$ ត្រង់ចំណុច $x = 0$ ។

ខ/ $f(x) = \dfrac{e^{x^2 - 3x + 2} - 1}{x - 2}$ ត្រង់ចំណុច $x = 2$ ។

គ/ $f(x) = \dfrac{\ln(x^2 - 6x + 10)}{(x - 3)^2}$ ត្រង់ចំណុច $x = 3$ ។

ឃ/ $f(x) = \dfrac{\sin \pi x}{1 - x^3}$ ត្រង់ចំណុច $x = 1$ ។

ង/ $f(x) = \dfrac{1 + \cos x}{(\pi - x)^2}$ ត្រង់ចំណុច $x = \pi$ ។

8/គេមានអនុគមន៍ $y = f(x)$ កំណត់លើចន្លោះ $\left[-\dfrac{\pi}{2}, \dfrac{\pi}{2}\right]$ ដោយដឹងថា ៖

$$f(x) = \begin{cases} \sin x + \dfrac{\sqrt{1 - \cos 2x}}{\sin x} & \text{បើ } x \neq 0 \\ \sqrt{2} & \text{បើ } x = 0 \end{cases}$$

តើអនុគមន៍ $f$ ជាប់ត្រង់ចំណុច $x = 0$ ឬទេ ?

9/ គេឲ្យសមីការដឺក្រេទីពីរ $ax^2+bx+c=0$ ដែល $a\neq 0$ ។

គេដឹងថាលេខមេគុណ $a,b,c$ ផ្ទៀងផ្ទាត់ $2a+3b+6c=0$ ។

ចូរបង្ហាញថាសមីការនេះមានឫសយ៉ាងតិចមួយនៅក្នុង $\left[0,\frac{2}{3}\right]$ ។

10/ ស្រាយបញ្ជាក់ថាសមីការ $(x^n-1)\cos x+\sqrt{2}\sin x-1=0$

យ៉ាងហោចណាស់មានឫសពិតមួយនៅចន្លោះ $[0,1]$ ។

11/ រកតម្លៃ A និង B ដែលធ្វើឲ្យអនុគមន៍ f កំណត់ដោយ ៖

$$f(x)=\begin{cases} Ax^2+5x-9 & \text{បើ } x<1 \\ B & \text{បើ } x=1 \\ (3-x)(A-2x) & \text{បើ } x>1 \end{cases}$$

ជាអនុគមន៍ជាប់លើ IR ។

12/ គេឲ្យអនុគមន៍ $f(x)=\dfrac{\cos\pi x}{1-2x}$ ដែល $x\neq\dfrac{1}{2}$

ក-ចូរគណនាលីមីត $\lim\limits_{x\to\frac{1}{2}} f(x)$ ។

ខ-តើf អាចមានអនុគមន៍បន្លាយតាមភាពជាប ត្រង់ $x=\dfrac{1}{2}$ ឬទេ ?

ជំពូកទី៣

# លំហាត់មានដំណោះស្រាយ

## លំហាត់ទី១

គេមានអនុគមន៍ $f(x) = \frac{a + b\cos x}{x^2}$ ដែល $x \neq 0$

ចូរកំណត់ $a$ និង $b$ ដើម្បីឲ្យ $\lim_{x\to 0} f(x) = 4$ ។

## ដំណោះស្រាយ

កំណត់ $a$ និង $b$ ៖

គេមាន $f(x) = \frac{a + b\cos x}{x^2}$ ដោយ $\cos x = 1 - 2\sin^2\frac{x}{2}$

នោះ $f(x) = \frac{a + b(1 - 2\sin^2\frac{x}{2})}{x^2} = \frac{(a + b) - 2b\sin^2\frac{x}{2}}{x^2}$

គេបាន $\lim_{x\to 0} f(x) = \lim_{x\to 0} \frac{(a + b) - 2b\sin^2\frac{x}{2}}{x^2}$

ដើម្បីឲ្យបាន $\lim\limits_{x\to 0} f(x) = 4$ គេត្រាន់តែឲ្យ $a + b = 0$

និង $\lim\limits_{x\to 0} \dfrac{-2b\sin^2 \frac{x}{2}}{x^2} = 4$ ឬ $\lim\limits_{x\to 0} \dfrac{\sin^2 \frac{x}{2}}{(\frac{x}{2})^2} \times (-\frac{b}{2}) = 8$

នាំឲ្យ $-\dfrac{b}{2} = 4$ ឬ $b = -8$ ហើយ $a + b = 0$ នោះ $a = 8$ ។

ដូចនេះ $a = 8$ , $b = -8$ ។

## លំហាត់ទី២

ចូរគណនាលីមីតខាងក្រោម៖

ក. $\lim_{x\to1}\left(\frac{1}{1-x}-\frac{3}{1-x^3}\right)$ ខ. $\lim_{x\to1}(\frac{1}{1-x}-\frac{n}{1-x^n})$

គ. $\lim_{x\to1}\left(\frac{m}{1-x^m}-\frac{n}{1-x^n}\right)$ ដែល $m$ និង $n$ ជាចំនួនគត់វិជ្ជមាន ។

## ដំណោះស្រាយ

ក. $\lim_{x\to1}\left(\frac{1}{1-x}-\frac{3}{1-x^3}\right)$

$$=\lim_{x\to1}\left[\frac{1}{1-x}-\frac{3}{(1-x)(1+x+x^2)}\right]=\lim_{x\to1}\left[\frac{(1+x+x^2)-3}{(1-x)(1+x+x^2)}\right]$$

$$=\lim_{x\to1}\frac{(x-1)+(x^2-1)}{(1-x)(1+x+x^2)}=\lim_{x\to1}\frac{(x-1)+(x-1)(x+1)}{-(x-1)(x^2+x+1)}$$

$$=\lim_{x\to1}\frac{1+(x+1)}{-(x^2+x+1)}=\frac{1+2}{-3}=-1$$

ដូចនេះ $\boxed{\lim_{x\to1}\left(\frac{1}{1-x}-\frac{3}{1-x^3}\right)=-1}$ ។

ខ. $\lim_{x\to 1}(\frac{1}{1-x}-\frac{n}{1-x^n})$

$$=\lim_{x\to 1}\left[\frac{1}{1-x}-\frac{n}{(1-x)(1+x+...+x^{n-1})}\right]$$

$$=\lim_{x\to 1}\frac{(1+x+...+x^{n-1})-n}{(1-x)(1+x+....+x^{n-1})}$$

$$=\lim_{x\to 1}\frac{(x-1)+....+(x^{n-1}-1)}{-(x-1)(1+x+...+x^{n-1})}$$

$$=\lim_{x\to 1}\frac{(x-1)+......+(x-1)(x^{n-2}+....+x+1)}{-(x-1)(1+x+.....+x^{n-1})}$$

$$=\lim_{x\to 1}\frac{1+.....+(x^{n-2}+....+x+1)}{-(1+x+.....+x^{n-1})}$$

$$=\frac{1+2+.....+(n-1)}{-n}=-\frac{n-1}{2}$$

គ. $\lim_{x\to 1}\left(\frac{m}{1-x^m}-\frac{n}{1-x^n}\right)$

$$=\lim_{x\to 1}\left(\frac{1}{1-x}-\frac{n}{1-x^n}\right)-\lim_{x\to 1}\left(\frac{1}{1-x}-\frac{m}{1-x^m}\right)$$

$$=\left(-\frac{n-1}{2}\right)-\left(-\frac{m-1}{2}\right)=\frac{-n+1+m-1}{2}=\frac{m-n}{2}$$

ដូចនេះ $\boxed{\lim_{x\to 1}\left(\frac{m}{1-x^m}-\frac{n}{1-x^n}\right)=\frac{m-n}{2}}$ ។

# លំហាត់ទី៣

គណនាលីមីត ៖

ក. $\lim\limits_{x\to 0}\dfrac{(1+x)^3-(3x+1)}{x^2}$

ខ. $\lim\limits_{x\to 0}\dfrac{(1+x)^n-(nx+1)}{x^2}$ , $n\in IN$

# ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 0}\dfrac{(1+x)^3-(3x+1)}{x^2}$

$$=\lim_{x\to 0}\frac{1+3x+3x^2+x^3-3x-1}{x^2}$$

$$=\lim_{x\to 0}\frac{3x^2+x^3}{x^2}$$

$$=\lim_{x\to 0}\left(3+x\right)=3$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{(1+x)^3-(3x+1)}{x^2}=3}$ ។

ខ. $\lim\limits_{x\to 0}\dfrac{(1+x)^n-(nx+1)}{x^2}$ , $n\in IN$

តាមរូបមន្តទ្វេធាញូតុន ៖

$$(1+x)^n = C_n^0 + C_n^1 x + C_n^2 x^2 + C_n^3 x^3 + ... + C_n^n x^n$$

$$= \lim_{x\to 0}\frac{1+nx+\dfrac{n(n-1)}{2}x^2 + C_n^3x^3 + .... + C_n^n x^n - nx - 1}{x^2}$$

$$= \lim_{x\to 0}\frac{\dfrac{n(n-1)}{2}x^2 + C_n^3x^3 + .... + C_n^n x^n}{x^2}$$

$$= \lim_{x\to 0}\left[\frac{n(n-1)}{2} + C_n^3 x + .... + C_n^n x^{n-2}\right] = \frac{n(n-1)}{2}$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{(1+x)^n-(nx+1)}{x^2} = \dfrac{n(n-1)}{2}}$ ។

# លំហាត់ទី៤

ចូរគណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x \to 1} \dfrac{3x^4 - 4x^3 + 1}{(x-1)^2}$

ខ. $\lim\limits_{x \to 1} \dfrac{nx^{n+1} - (n+1)x^n + 1}{(x-1)^2}$ , $n \in IN$

# ដំណោះស្រាយ

ក. $\lim\limits_{x \to 1} \dfrac{3x^4 - 4x^3 + 1}{(x-1)^2}$

$$= \lim_{x \to 1} \frac{(3x^4 - 3x^3) - (x^3 - 1)}{(x-1)^2}$$

$$= \lim_{x \to 1} \frac{3x^3(x-1) - (x-1)(x^2 + x + 1)}{(x-1)^2}$$

$$= \lim_{x \to 1} \frac{3x^3 - x^2 - x - 1}{x-1} = \lim_{x \to 1} \frac{(x^3 - x^2) + (x^3 - x) + (x^3 - 1)}{x-1}$$

$$= \lim_{x \to 1} \frac{x^2(x-1) + x(x-1)(x+1) + (x-1)(x^2 + x + 1)}{x-1}$$

$$= \lim_{x \to 1} \left[ x^2 + x(x+1) + (x^2 + x + 1) \right] = 1 + 2 + 3 = 6$$

ដូចនេះ $\boxed{\lim\limits_{x \to 1} \dfrac{3x^4 - 4x^3 + 1}{(x-1)^2} = 6}$ ។

ខ. $\lim\limits_{x\to 1}\dfrac{nx^{n+1}-(n+1)x^{n}+1}{(x-1)^{2}}$ , $n\in IN$

$$=\lim_{x\to 1}\frac{nx^{n}(x-1)-(x-1)(x^{n-1}+....+x^{2}+x+1)}{(x-1)^{2}}$$

$$=\lim_{x\to 1}\frac{(x^{n}-x^{n-1})+....+(x^{n}-x)+(x^{n}-1)}{x-1}$$

$$=\lim_{x\to 1}\frac{x^{n-1}(x-1)+...+x(x-1)(x^{n-2}+...+x+1)+(x-1)(x^{n-1}+...+x+1)}{x-1}$$

$$=\lim_{x\to 1}\left[x^{n-1}+....+x(x^{n-2}+...+x+1)+...(x^{n-1}+...+x+1)\right]$$

$$=1+2+....+(n-1)+n=\frac{n(n+1)}{2}$$

ដូចនេះ $\lim\limits_{x\to 1}\dfrac{nx^{n+1}-(n+1)x^{n}+1}{(x-1)^{2}}=\dfrac{n(n+1)}{2}$ ។

# លំហាត់ទី៥

គណនាលីមីតខាងក្រោម ៖

$$A=\lim_{x\to 2}\left(\sqrt[6]{\frac{6x^4-12x^3-x+2}{x+2}}\times\frac{\sqrt[3]{x^3-\sqrt{x^2+60}}}{\sqrt{x^2-\sqrt[3]{x^2+60}}}\right)$$

# ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

$$A=\lim_{x\to 2}\left(\sqrt[6]{\frac{6x^4-12x^3-x+2}{x+2}}\times\frac{\sqrt[3]{x^3-\sqrt{x^2+60}}}{\sqrt{x^2-\sqrt[3]{x^2+60}}}\right)$$

$$U=6x^4-12x^3-x+2$$

$$=6x^3(x-2)-(x-2)=(x-2)(6x^3-1)$$

$$V=x^3-\sqrt{x^2+60}=\frac{x^6-x^2-60}{x^3+\sqrt{x^2+60}}$$

$$=\frac{W}{x^3+\sqrt{x^2+60}}$$

ដែល $W=x^6-x^2-60=(x^6-64)-(x^2-4)$

$$= (x^2-4)(x^4+4x^2+16)-(x^2-4)$$
$$= (x-2)(x+2)(x^4+4x^2+15)$$

$$T = x^2 - \sqrt[3]{x^2+60} = \frac{x^6-x^2-60}{x^4+x^2\sqrt[3]{x^2+60}+\sqrt[3]{(x^2+60)^2}}$$

$$= \frac{W}{x^4+x^2\sqrt[3]{x^2+60}+\sqrt[3]{(x^2+60)^2}}$$ ។

$$A = \lim_{x\to 2}\left(\sqrt[6]{\frac{U}{x+2}}\times\frac{\sqrt[3]{V}}{\sqrt{T}}\right) = \lim_{x\to 2}\left(\sqrt[6]{\frac{U}{x+2}\cdot\frac{V^2}{T^3}}\right)$$

$$= \lim_{x\to 2}\left(\sqrt[6]{\frac{(x-2)(6x^3-1)}{x+2}\cdot\frac{W^2}{(x^3+\sqrt{x^2+60})^2}\frac{(x^4+x^2\sqrt[3]{x^2+60}+\sqrt[3]{(x^2+60)^2})^3}{W^3}}\right)$$

$$= \lim_{x\to 2}\left(\sqrt[6]{\frac{(x-2)(6x^3-1)(x^4+x^2\sqrt[3]{x^2+60}+\sqrt[3]{(x^2+60)^2})^3}{(x+2)(x^3+\sqrt{x^2+60})^2(x-2)(x+2)(x^4+4x^2+15)}}\right)$$

$$= \lim_{x\to 2}\left(\sqrt[6]{\frac{(6x^3-1)(x^4+x^2\sqrt[3]{x^2+60}+\sqrt[3]{(x^2+60)^2})^3}{(x+2)^2(x^3+\sqrt{x^2+60})^2(x^4+4x^2+15)}}\right) = \sqrt[6]{\frac{47.48^3}{16.16^2.47}} = \sqrt{3}$$

ដូចនេះ $A = \sqrt{3}$ ។

# លំហាត់ទី៦

គណនាលីមីត $A=\lim_{x\to 1}\frac{x^2-1+\sqrt{x^3+1}-\sqrt{x^4+1}}{x-1+\sqrt{x+1}-\sqrt{x^2+1}}$

# ដំណោះស្រាយ

$$A=\lim_{x\to 1}\frac{x^2-1+\sqrt{x^3+1}-\sqrt{x^4+1}}{x-1+\sqrt{x+1}-\sqrt{x^2+1}}$$

$$=\lim_{x\to 1}\frac{(x-1)(x+1)+\frac{x^3+1-x^4-1}{\sqrt{x^3+1}+\sqrt{x^4+1}}}{(x-1)+\frac{x+1-x^2-1}{\sqrt{x+1}+\sqrt{x^2+1}}}$$

$$=\lim_{x\to 1}\frac{(x-1)(x+1)-\frac{x^3(x-1)}{\sqrt{x^3+1}+\sqrt{x^4+1}}}{(x-1)-\frac{x(x-1)}{\sqrt{x+1}+\sqrt{x^2+1}}}$$

$$=\lim_{x\to 1}\frac{(x-1)[x+1-\frac{x^3}{\sqrt{x^3+1}+\sqrt{x^4+1}}]}{(x-1)(1-\frac{x}{\sqrt{x+1}+\sqrt{x^2+1}})}$$

$$=\lim_{x\to 1}\frac{x+1-\frac{x^3}{\sqrt{x^3+1}+\sqrt{x^4+1}}}{1-\frac{x}{\sqrt{x+1}+\sqrt{x^2+1}}}=\frac{2-\frac{1}{2\sqrt{2}}}{1-\frac{1}{\sqrt{2}}}=\frac{7+3\sqrt{2}}{2}$$

# លំហាត់ទី៧

ចូរគណនាលីមីតខាងក្រោមនេះ

ក. $\lim\limits_{x\to 0}\dfrac{1-\cos^3 2x}{x\sin x}$

ខ. $\lim\limits_{x\to 0}\dfrac{\tan x-\sin x}{x^3}$

គ. $\lim\limits_{x\to 0}\dfrac{2\sin x-\sin 2x}{3\sin x-\sin 3x}$

ឃ. $\lim\limits_{x\to 0}\dfrac{\cos 2x-\cos 4x}{1-\cos 2x\cos 4x}$

ង. $\lim\limits_{x\to 0}\dfrac{1-\cos(1-\cos x)}{x^4}$

ច. $\lim\limits_{x\to 0}\dfrac{1-\cos x\sqrt{\cos 2x}}{x^2}$

ឆ. $\lim\limits_{x\to 0}\dfrac{1-\sqrt{\cos x}}{1-\sqrt{\cos 2x}}$

ជ. $\lim\limits_{x\to 0}\dfrac{\sqrt{2}-\sqrt{1+\cos x}}{x.\tan x}$

ឈ. $\lim\limits_{x\to 0}\dfrac{\sqrt{1+\sin^2}-\cos x}{\sqrt{\cos x-\sqrt{\cos 3x}}}$

ញ. $\lim\limits_{x\to 0}\dfrac{1-\sqrt[3]{\cos 3x}}{x(1-\cos\sqrt{x})}$

# ដំណោះស្រាយ

គណនាលីមីត៖

ក. $\lim\limits_{x\to 0}\dfrac{1-\cos^3 2x}{x\sin x}$

តាមរូបមន្ត $a^3-b^3=(a-b)(a^2+ab+b^2)$

